# ព្រះរាជក្រម

នស/រកម/០៣០៥/០០៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០១/នស/១៩៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០០២ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

2/12

# ច្បាប់

# ស្តីពី

# ការទូទាត់ថវិកាទូទៅរបស់រដ្ឋ

# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានយល់ព្រមតាមការអនុវត្តនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០១ ។ ការអនុវត្តនេះ លេចចេញជាលទ្ធផលដូចមានចែងក្នុងតារាងសរុបខាងក្រោមនេះ ៖

ឯកតា :លានរៀល

| កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០២ | ការអនុវត្តថវិកា ឆ្នាំ ២០០២ |
|---|---|---|
| សរុបចំណូល [១] | ២.៦៣៦.០០០ | ២.៩៧៣.៨០១ |
| សរុបចំណាយ | ២.៦៣៦.០០០ | ២.៩៧២.៣៤២ |
| ចំនួនអតិរេកនៃគណនេយ្យចំណូល/ ចំណាយ | — | - ១.១៥៩ |
| កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាដែលបានអនុវត្តដោយរតនាគារជាតិ | | |
| ចំណូលថវិកា | ១.៩៣៦.០០០ | ១.៩២៣.៩៦៨ |
| • ចំណូលចរន្ត | ១.៧៩១.០០០ | ១.៧២៨.៩៩៤ |
| • ចំណូលជាមូលធនក្នុងប្រទេស | ២៥.០០០ | ១៦.៣០៥ |
| • ចំណូលជាមូលធនក្រៅប្រទេស | ១២០.០០០ | ១៧៨.៦៦៩ |
| ចំណាយថវិកា | ១.៩៣៦.០០០ | ១.៩២២.៤០៨ |
| • ចំណាយចរន្ត | ១.៥៧៦.០០០ | ១.៥៧៤.១១៤ |
| • ចំណាយជាមូលធន | ៣៦០.០០០ | ៣៤៨.២៩៦ |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលបានអនុវត្តក្រៅរតនាគារជាតិ | | |
| • ធនធានជាមូលធនសំរាប់គំរោងដោយហិរញ្ញប្បទាន ក្រៅប្រទេសផ្ទាល់ | ៧០០.០០០ | ១.០៤៩.៨៣៣ |
| • ចំណាយជាមូលធនដោយធនធាន សំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៧០០.០០០ | ១.០៤៩.៨៣៣ |

[១] ក្នុងនោះមានវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលបានលើកឡើងនេះ គ្រាន់តែជាការបង្ហាញបញ្ជាក់ប៉ុណ្ណោះ ពីព្រោះកិច្ចប្រតិបត្តិការដែលបានអនុវត្តផ្ទាល់ដោយហិរញ្ញប្បទានក្រៅប្រទេស មិនឆ្លងកាត់រតនាគារជាតិ និង មិនបានចុះកិច្ចបញ្ជីការគណនេយ្យ នៅក្នុងរបាយការណ៍រតនាគារជាតិទេ កិច្ចប្រតិបត្តិការនេះ គឺជាលទ្ធផលដែលសំរេចបានដោយមានទំនាក់ទំនងផ្ទាល់ ជាមួយអ្នកផ្តល់មូលនិធិ ។

មាត្រា ២.-

ចំណូលថវិកា ដែលបានអនុវត្តដោយរតនាគារជាតិ ត្រូវបានលំអិតតាមមាតិកាថវិកា នៅក្នុងតារាង "ក" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

ចំណាយថវិកា ដែលបានអនុវត្តដោយរតនាគារជាតិ ក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០២ ត្រូវបានលំអិតតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែល និង តាមជំពូកនៅក្នុង តារាង "ខ" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

តារាង "ខ១" ដែលភ្ជាប់មកជាមួយច្បាប់នេះ គឺជាបញ្ជីនៃចំណាយវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្នុងប្រទេស ដែលសំរេចបានក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០២ និងដែល បានបែងចែកតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែល ។

លទ្ធផលសំរេចបានស្តីពីវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០២ ចំពោះចំណូលត្រូវបានលំអិតតាមមាតិកាថវិកាដូចមាន នៅក្នុងភាគទី II នៃតារាង "ក" និងចំពោះចំណាយត្រូវបានលំអិតនៅក្នុងតារាង "ខ២" ដូចមានជូនភ្ជាប់មកជាមួយច្បាប់នេះ ។

## ជំពូកទី ២
## បទប្បញ្ញត្តិ
## ស្តីពីកិច្ចប្រតិបត្តិការថវិកា

មាត្រា ៣.-

ការប្រមូលចំណូល ជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋពីពន្ធដារ វិភាគទាន អាករ ផលិតផល និង ផលទុន ព្រមទាំងការសំរេចបាននូវអំណោយ មូលនិធិឧបត្ថម្ភ និង ធនធានដែលបានមកពីការខ្ចី ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២ ។

មានចំនួនទឹកប្រាក់សរុប.................................................................... ១.៩៣៦.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់.......................... ១.៩២៣.៥៦៨ លានរៀល

ដូច្នេះមានចំណូលខ្វះចំនួន.......................................... (-) ១២.៤៣២ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តន៍ដូចតទៅ ៖

ចំណូលចរន្ត :

- គំរោង........................... ១.៧៩១.០០០ លានរៀល
- ការសំរេចបាន.......... ១.៧២៧.៥៩៨ លានរៀល
- មានចំនួនខ្វះ.......... (-) ៦៣.៤០២ លានរៀល

ចំណូលជាមូលធនក្នុងប្រទេស :

- គំរោង................................ ២៥.០០០ លានរៀល
- ការសំរេចបាន................... ១៦.៣០៥ លានរៀល
- មានចំនួនខ្វះ.................. (-) ៨.៦៩៥ លានរៀល

ចំណូលជាមូលធនក្រៅប្រទេស :

- គំរោង................................១២០.០០០ លានរៀល
- ការសំរេចបាន.................. ១៧៩.៦៦៥ លានរៀល
- មានចំនួនលើស....... (+) ៥៩.៦៦៥ លានរៀល

**មាត្រា ៤.-**

ចំណាយថវិកាទូទៅរបស់រដ្ឋ ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ មានចំនួនទឹកប្រាក់សរុប...................................... ១.៩៣៦.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់........ .................... ១.៩២២.៤០៩ លានរៀល

ដូច្នេះមានចំណាយខ្វះឥណទានថវិកាចំនួន........... (-)១៣.៥៩១ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តន៍ដូចតទៅ ៖

ចំណាយចរន្ត :

- គំរោង ...................... ១.៥៧៦.០០០ លានរៀល
- ការសំរេចបាន............. ១.៥៧៤.១១៤លានរៀល
- មានចំនួនខ្វះ.................. (-)១.៨៨៦ លានរៀល

ចំណាយជាមូលធននៃវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្នុងប្រទេស :

- គំរោង............................ ៣៦០.០០០ លានរៀល
- ការសំរេចបាន................ ៣៤៨.២៩៦ លានរៀល
- មានចំនួនខ្វះ............... (-)១១.៧០៤ លានរៀល

ចំណាយជាមូលធននៃការវិលស់បំណុល :

- គំរោង.......................................២៥.០០០ លានរៀល
- ការសំរេចបាន.......................៩.១២៧ លានរៀល
- មានចំនួនខ្វះ.............. (-)១៥.៨៧៣ លានរៀល

**មាត្រា ៥.-**

ការអនុវត្តកិច្ចប្រតិបត្តិការចំណូល និង ចំណាយតាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ដែលបានសំរេចដោយរតនាគារជាតិដូចមានចែងនៅក្នុងមាត្រា ៣ និង មាត្រា ៤ នៃច្បាប់នេះ បានបង្ហាញជាលទ្ធផលនូវអតិរេកគណនេយ្យនៃចំណូល និង ចំណាយដូចតទៅ ៖

- ចំណូលថវិកា ដែលបានសំរេចដោយរតនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ មានចំនួន.......................................................................... ១.៩២៣.៥៦៨ លានរៀល
- ចំណាយថវិកា ដែលបានសំរេចដោយរតនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ មានចំនួន.......................................................................... ១.៩២២.៤០៩ លានរៀល
- អតិរេកគណនេយ្យពិតនៃចំណូល និងចំណាយ.... (+)១.១៥៩លានរៀល

អតិរេកគណនេយ្យនេះ គឺជាលទ្ធផលនៃ :

- អតិរេកនៃចំណូលចរន្ត និង ចំណាយចរន្ត.(+)១៥៣.៤៨៤ លានរៀល
- និងឱនភាពនៅក្នុងកិច្ចប្រតិបត្តិការជាមូលធន.. (-)១៥២.៣២៥លានរៀល

ដោយអនុលោមទៅតាមបទប្បញ្ញត្តិក្នុងមាត្រា ៥៧ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ ន.ស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ អតិរេកគណនេយ្យនៃចំណូល និង ចំណាយសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ មានចំនួនទឹកប្រាក់ (+) ១.១៥៩ លានរៀល ត្រូវបានកត់ត្រានៅក្នុងគណនីលទ្ធផល ដែលបានបើកនៅក្នុងលេខនានៃរតនាគារជាតិ ។

# ជំពូកទី ៣

# បទប្បញ្ញត្តិ

# ស្តីពីវិនិយោគសាធារណៈ

# ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់

# ដែលបានអនុវត្តក្រៅរតនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២

**មាត្រា ៦.-**

វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលបានអនុវត្តក្រៅរត-នាគារជាតិ និងដែលបានគ្រោងទុក សរុបចំណូលស្មើនឹងសរុបចំណាយសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ មានចំនួនទឹកប្រាក់........................................................................ ៧០០.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់.......................... ១.០៤៩.៩៣៣ លានរៀល

ដូច្នេះមានចំនួនលើស............................................ (+)៣៤៩.៩៣៣ លានរៀល

# ជំពូកទី ៤

# បទប្បញ្ញត្តិស្តីពី

# តុល្យភាពហិរញ្ញវត្ថុសាធារណៈ

# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២

**មាត្រា ៧.-**

តុល្យភាពហិរញ្ញវត្ថុសាធារណៈជាស្ថាពរនៃថវិកាទូទៅរបស់រដ្ឋ បានបង្ហាញនូវប្រភេទនៃកិច្ចប្រតិបត្តិការដូចតទៅ ៖

- កិច្ចប្រតិបត្តិការថវិកា : តារាង “ក” : ចំណូលថវិកាទូទៅរបស់រដ្ឋ និងតារាង “ខ” ចំណាយថវិកាទូទៅរបស់រដ្ឋ ។
- កិច្ចប្រតិបត្តិការនៃរតនាគារជាតិ ។
- ទំនាក់ទំនងហិរញ្ញវត្ថុរបស់រដ្ឋ ជាមួយនឹងធនាគារជាតិនៃកម្ពុជា ។

តុល្យភាពហិរញ្ញវត្ថុដែលសំរេចបានជាស្ថាពរ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ បានឆ្លុះបញ្ចាំងនៅក្នុងតារាង នៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ ដូចខាងក្រោម ៖

ឯកតា :លានរៀល

| តារាងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ | ចំនួនទឹកប្រាក់ | ចំនួនលើស (+)/ ឱនភាព (-) |
|---|---|---|
| I- ចំណូលក្នុងប្រទេស | ១.៧៤៣.៩០៣ | |
| ១.ចំណូលចរន្ត | ១.៧២៧.៥៩៨ | |
| ២.ចំណូលជាមូលធនក្នុងប្រទេស (ឯកជនភាវូបនីយកម្ម) | ១៦.៣០៥ | |
| II- ចំណាយថវិកា | ២.៩៦៣.២១៥ | |
| ១.ចំណាយចរន្ត | ១.៥៧៤.១១៤ | |
| ២.ចំណាយជាមូលធន [២] | ១.៣៨៩.១០១ | |
| ក្នុងនោះ : | | |
| ❖ វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ៣៣៨.៣៦៨ | |
| -ដោយមូលនិធិថវិកា | ២៨១.៤២០ | |
| • គំរោងវិនិយោគ (សាងសង់, ទិញសម្ភារៈ) | ២៣០.៩៩៨ | |
| • បរិភាគរួមចំណែកជាមួយវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៥០.៤២២ | |
| -ដោយមូលនិធិក្រៅប្រទេសដែលមានការយល់ព្រមជាមុនពីអ្នកផ្ដល់ជំនួយ | ៥៦.៩៤៨ | |
| ❖ វិនិយោគសាធារណៈដោយហិរញ្ញប្បទានពីក្រៅប្រទេសផ្ទាល់(ជំនួយគំរោងការ) | ១.០៤៩.៩៣៣ | |
| អតិរេកនៃថវិកាចរន្ត (តាមនិយមន័យសន្សាផ្ទាល់) | | (+)១៥៣.៤៨៤ |
| ឱនភាពនៃថវិកាទូទៅ (តាមនិយមន័យសន្សាផ្ទាល់) | | (-)១.២១៩.៣១២ |
| III-កំណែតម្រូវ | | (+)១៤.៩៣៩ [៣] |
| អតិរេកនៃថវិកាចរន្ត (តាមនិយមន័យបេឡា) | | (+)១៦៨.៥២៣ |
| ឱនភាពនៃថវិកាទូទៅ (តាមនិយមន័យបេឡា) | | (-)១.២០៤.៣៧៣ |
| IV- ហិរញ្ញប្បទាននៃឱនភាព | | (+)១.២០៤.៣៧៣ |
| ១. ហិរញ្ញប្បទានក្រៅប្រទេស | | (+)១.២៥០.៨៩៩ |
| • ជំនួយទ្រទ្រង់ថវិកាដែលមានការយល់ព្រមជាមុនពីអ្នកផ្ដល់ជំនួយ | | (+)១៧៩.៦៦៥ |
| • ជំនួយគំរោងការ | | (+)១.០៧៩.១៣៩ [៤] |
| • ការរំលស់បំណុលបរទេស | | (-)៧.៩២៤ |
| ២. ហិរញ្ញប្បទានក្នុងប្រទេស | | (-)១៦០.៩៤០ |
| • ហិរញ្ញប្បទានធនាគារ | | (-)១០៤.៧៩៤ |
| ក្នុងនោះ -ខ្ចីពីធនាគារ | | - |
| -ការរំលស់បំណុលក្នុងប្រទេស | | (-)១.៧៧៣ |
| • ប្រាក់បញ្ញើផ្សេងៗទៀតនៃរតនាគារ | | (-)៦.៩៧១ |
| • វិស័យឯកជន | | (-)៤៥.៩៣២ |
| • លំអៀងគណនីរវាងធនាគារជាតិ និង ហិរញ្ញវត្ថុ | | (-)២.៨៤៣ |
| ៣. កិច្ចប្រតិបត្តិការកំពុងដំណើរការ | | (+)១១៣.៧១៤ |

[២] មិនបានគិតការរំលស់បំណុល ៩.១២៧ លានរៀល។

[៣] បំរែបំរួលសុទ្ធនៃអាណត្តិបើកប្រាក់ ដែលមានសល់មិនទាន់បានបើកផ្ដល់នៅរតនាគារ និង បុរេប្រទានត្រូវធ្វើឱយតភាវូបនីយកម្ម។

[៤] ក្នុងនោះមានទឹកប្រាក់ចំនួន ២៩.២០៥ លានរៀល ត្រូវរង់ចាំការប្រើប្រាស់ ។

# ជំពូកទី ៥

# បទប្បញ្ញត្តិស្តីពី

# ការទូទាត់ថវិការបស់ខេត្ត ក្រុង

# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២

**មាត្រា ៨.–**

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ១៨ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យ-សម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម.០២៩៨.០៣, ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ និង មាត្រា ១២ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ត្រូវបានយល់ព្រមតាមការអនុវត្ត នូវកិច្ចប្រតិបត្តិការចំណូល និង ចំណាយថវិការបស់ខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ដែលលេចចេញជាលទ្ធផល ដូចបានបង្ហាញនៅក្នុងតារាងខាងក្រោមនេះ ៖

ឯកតា : រៀល

| កិច្ចប្រតិបត្តិការចំណូល និង ចំណាយថវិការបស់ខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០២ | ការអនុវត្តថវិកា ខេត្ត ក្រុងឆ្នាំ ២០០២ | លើស(+) ខ្វះ (-) |
|---|---|---|---|
| សរុបចំណូល | ៧៥.000.000.000 | ៨១.៥៥៤.២៩៧.១៩៣ | +៦.៥៥៤.២៩៧.១៩៣ |
| សរុបចំណាយ | ៧៥.000.000.000 | ៧៩.៧៤៥.៩៤៣.៨០៨ | +៤.៧៤៥.៩៤៣.៨០៨ |
| អតិរេកគណនេយ្យនៃចំណូល និង ចំណាយ | | ១.៨០៨.៣៥៣.៣៨៥ | +១.៨០៨.៣៥៣.៣៨៥ |
| កិច្ចប្រតិបត្តិការនៃថវិការបស់ខេត្ត ក្រុង | | | |
| I. ចំណូលថវិកា | ៧៥.000.000.000 | ៨១.៥៥៤.២៩៧.១៩៣ | +៦.៥៥៤.២៩៧.១៩៣ |
| – ចំណូលចរន្ត | ៧៥.000.000.000 | ៨១.៥៥០.៧៨៧.១៩៣ | ៦.៥៥០.៧៨៧.១៩៣ |
| • ចំណូលសារពើពន្ធ | ៣៦.000.000.000 | ៤១.៧៧៦.២៣១.៧៥៦ | +៥.៧៧៦.២៣១.៧៥៦ |
| • ចំណូលមិនមែនសារពើពន្ធ | ៨.000.000.000 | ៨.៣៦៩.៥៥៥.៤៣៧ | +៣៦៩.៥៥៥.៤៣៧ |
| • ឧបត្ថម្ភពីថវិការដ្ឋ | ៣១.000.000.000 | ៣១.៤០៥.000.000 | +៤០៥.000.000 |
| – ចំណូលជាមូលធន | 0 | ៣.៥១០.000 | +៣.៥១០.000 |
| • ចំណូលជាមូលធនផ្ទៃក្នុង | 0 | ៣.៥១០.000 | +៣.៥១០.000 |
| • ចំណូលជាមូលធននៃវិនិយោគដោយថវិការដ្ឋ (កម្មវិធីសិលា) | 0 | 0 | 0 |
| II. ចំណាយថវិកា | ៧៥.000.000.000 | ៧៩.៧៤៥.៩៤៣.៨០៨ | +៤.៧៤៥.៩៤៣.៨០៨ |
| – ចំណាយចរន្ត | ៧៥.000.000.000 | ៧៩.៧៤៥.៩៤៣.៨០៨ | +៤.៧៤៥.៩៤៣.៨០៨ |
| – ចំណាយជាមូលធន | 0 | 0 | 0 |
| III. អតិរេកថវិកា | 0 | ១.៨០៨.៣៥៣.៣៨៥ | +១.៨០៨.៣៥៣.៣៨៥ |

**មាត្រា ៩.–**

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ២២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យ-សម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស.រកម.០២៩៨.០៣, ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ អតិរេកនៃថវិការបស់ខេត្ត ក្រុង ដែលមានចំនួនទឹកប្រាក់ ១.៨០៨.៣៥៣.៣៨៥ រៀល ត្រូវបានបង់ចូលថវិកាទូទៅរបស់រដ្ឋ ។

## ជំពូកទី ៦

## បទប្បញ្ញត្តិស្តីពី

## និយ័តភាវូបនីយកម្ម

## នៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែម

## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២

**មាត្រា ១០.–**

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ៤៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះ-រាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ផ្អែកតាមលិខិតលេខ ៣៧៦ រស ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៣ របស់រដ្ឋសភា ត្រូវបានអនុម័តយល់ព្រមផ្តល់ឥណទានថវិកាបន្ថែមដល់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ចំនួន ៣.០៧២ លានរៀល សំរាប់ចំណាយរៀបចំកិច្ចប្រជុំកំពូលអាស៊ានឆ្នាំ ២០០២ ។

## អវសានបញ្ញត្តិ

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១២.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០០៥

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.០៥០៣.១៤១

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
**ហត្ថលេខា**
**គាត ឈន់**

លេខ ៖ [illegible] ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ឆាយ តាន់**